# ការគណនាប្រាក់ខែប្រចាំខែសម្រាប់បុគ្គលិក

ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៥

**លោកស្រី ឈិត ពិសិទ្ធ**
DCA Cambodia

# ១) តើការគណនាប្រាក់ខែប្រចាំខែរបស់បុគ្គលិកត្រូវផ្តោតលើកត្តាអ្វីខ្លះ?

# ក. កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ

១. សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយនិយោជក៖

| លរ | កម្រិតប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ (គិតជារៀល) | អត្រាពន្ធ |
|---|---|---|
| ១ | ពី ០ ដល់ ១.៥០០.០០០ | ០% |
| ២ | ពី១.៥០០.០០១ ដល់ ២.០០០.០០០ | ៥% |
| ៣ | ពី២.០០០.០០២ ដល់ ៨.៥០០.០០០ | ១០% |
| ៤ | ពី៨.៥០០.០០១ ដល់ ១២.៥០០.០០០ | ១៥% |
| ៥ | លើសពី ១២.៥០០.០០០ | ២០% |

២. សម្រាប់និយោជិតអនិវាសនជន ប្រាក់ពន្ធត្រូវកាត់ទុកដោយអ្នកបើកប្រាក់អោយ តាមអត្រា២០% លើរាល់ការទូទាត់ប្រាក់បៀវត្សជាប់ពន្ធដូចចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា**ទី៤៦** នៃច្បាប់សារពើពន្ធ។

# ខ. ព័ត៌មានទាក់ទងនឹងប្រាក់បៀវត្សប្រចាំខែ

- ប្រាក់ខែគោល (basic salary)៖ កិច្ចសន្យាការងារ ឬព័ត៌មាននៃប្រាក់បៀវត្សប្រចាំខែ
- ប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ (Bonuses or 13th months)
- ប្រាក់បន្ថែមម៉ោង
- ប្រាក់ឧបត្ថម្ភផ្សេងៗ (ថ្លៃទូរស័ព្ទ ថ្លៃធ្វើដំណើរ ឬអាហារ ។ល។)
- បេឡារបបសន្តិសុខសង្គម (ផ្នែកសុខភាព ផ្នែកគ្រោះថ្នាក់ការងារ និងរបបសោធន៍)
- កញ្ចប់សន្សំផ្សេងៗ (provident fund) ប្រសិនបើមាន
- បំណុលផ្សេងៗ (Loan or outstanding cash advance) ប្រសិនបើមាន

# ២) តើបុគ្គលិកធនធានមនុស្ស និងបុគ្គលិកផ្នែកហិរញ្ញវត្ថុត្រូវសហការគ្នាយ៉ាងដូចម្តេច ដើម្បីធានាថា ការគណនាប្រាក់ខែពិតជាត្រឹមត្រូវតាមច្បាប់ស្តីពីការងារ?

# តួនាទីរបស់ផ្នែកធនធានមនុស្ស (ទទួលបន្ទុកប្រាក់ខែ)

- ផ្តល់នូវព័ត៌មានប្រាក់ខែ បច្ចុប្បន្នភាពចំនួនបុគ្គលិក ឬចែករំលែកកិច្ចសន្យាការងារថ្មី ឬលិខិតឡើងប្រាក់បៀវត្សផ្សេងៗប្រសិនបើមាន (ជាឯកសារគាំទ្រចំពោះបច្ចុប្បន្នភាព)
- គណនាអត្រាប្រាក់បន្ថែមម៉ោង (សម្រាប់តួនាទីដែលទទួលបាន ទៅតាមការកំនត់ផ្ទៃក្នុង ឧទា. អ្នកបើកបរ ឬអ្នកយាម)
- អត្រាប្តូរប្រាក់សម្រាប់ពន្ធប្រាក់បៀវត្សពីធនាគារជាតិ ចេញថ្ងៃទី១៥នៃខែនីមួយៗ ឬមុនប្រសិនបើចំចុងសប្តាហ៍ ឬថ្ងៃបុណ្យ
- អត្រាប្តូរប្រាក់សម្រាប់បេឡារបបសន្តិសុខសង្គមពីNSSF ចេញ១ខែម្តង

# តួនាទីរបស់ផ្នែកធនធានមនុស្ស (ទទួលបន្ទុកប្រាក់ខែ) (ត)

- អត្រាប្តូរប្រាក់ផ្សេងទៀតបើបុគ្គលិកបរទេសដែលទទួលបៀវត្សម្ចាស់ជំនួយផ្សេង មិនមែនជាប្រាក់ដុល្លារអាមេរិក
- ដល់ពេលវេលានៃការផ្តល់អត្ថប្រយោជន៍ ដូចជាប្រាក់ខែទី១៣ ប្រាក់អតីតភាពការងារ ខែ៦ និងខែ១២ ។ល។
- គណនាប្រាក់ឈប់សម្រាកប្រចាំឆ្នាំ(Annual Leave) សំរាប់បុគ្គលិកចប់កិច្ចសន្យា និងប្រាក់បំណាច់ផ្សេងៗ

# តួនាទីរបស់ផ្នែកហិរញ្ញវត្ថុ (ទទួលបន្ទុកប្រាក់ខែ)

- ត្រួតពិនិត្យទម្រង់ប្រាក់ខែ
- តួលេខប្រាក់ខែ
- ប្រភេទកិច្ចសន្យា
- បន្ថែមប្រាក់ខែបុគ្គលិកបរទេស បើសិនមិនបើកប្រាក់នៅកម្ពុជា (សម្រាប់អង្គការអន្តរជាតិ ១ចំនួន)
- ត្រួតពិនិត្យការកាត់បន្ថយមូលដ្ឋានគិតពន្ធសម្រាប់កូនក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ចំនួន ១៥០០០០ រៀលសំម្រាប់តែម្នាក់ក្នុងមួយខែ
- ការបូកបន្ថែម NSSF និងដកចេញពីប្រាក់ខែសរុប មុនពេលគិតពន្ធ
- ពិនិត្យមើលអត្រាត្រូវបង់ NSSF
- មើលរូបមន្តសម្រាប់កាត់ពន្ធ និងចំនួនត្រូវលើកលែងសម្រាប់ប្រាក់អតីតភាពការងាររៀងរាល់៦ខែ ដោយដក២លានរៀលចេញ។ល។

# គម្រូនៃការគណនាអតីតភាពការងារ

| No. | Stafff Name | Dat of hiring | Contract type | Basic Salary | Phone | Transpo rtation | Provide nt Fund | Bonus | Acting allowan ce | Salary + benefits | Daily rate devided by 22 days | Seniority 2025 (Jan-Jun): 7.5 days |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | Ms. Kanha | 1-Jan-23 | UDC | 1,500 | 15 | 30 | | 125 | | 1,670 | 75.91 | 569.32 |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

**សំគាល់៖** កម្មករនិយោជិតពេញសិទ្ធិដែលបានបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន២១ ថ្ងៃ ត្រូវចាត់ទុកថាបំពេញការងារបាន១ខែពេញ ដែលអាចទទួលបានប្រាក់បំណាច់អតីតភាពការងារ ។

# សូមអរគុណ!